00399820

E159/6

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង

| ឯកសារដើម |
| --- |
| DOCUMENT RECEIVED/DOCUMENT REÇU |
| ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 10 / NOV / 2009 |
| ម៉ោង (Time/Heure): 15:00 |
| មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A. Duy |

## សេចក្តីពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ : ០០១/១៨-០៧-២០០៧-អវតក/អជសដ
ដាក់ជូន : អង្គជំនុំជម្រះសាលាដំបូង
កាលបរិច្ឆេទ : ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៩
ភាគីដាក់ឯកសារ : សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម២)
ភាសាដើម : ភាសាអង់គ្លេស [ភាសាខ្មែរ និងភាសាបារាំង ជាអត្ថបទបកប្រែ]

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ : សាធារណៈ
ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ :
ស្ថានភាពចំណាត់ថ្នាក់ :
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន :
ឈ្មោះមន្ត្រីកត់ត្រា :
ហត្ថលេខា :

| ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម |
| --- |
| CERTIFIED COPY/COPIE CERTIFIÉE CONFORME |
| ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 12 / 11 / 2009 |
| មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA |

## ការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល
## ដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម២)

**ដាក់ជូនដោយ៖**

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**

លោក ហុង គឹមសួន

លោក គង់ ពិសី

លោក លោក យ៉ុង ផានិត

កញ្ញា Silke STUDWINSKY

**ជូនចំពោះ៖**

**អង្គជំនុំជម្រះសាលាដំបូង:**

ចៅក្រម **និល ណុន** ជាប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម **យ៉ា សុខន**

ចៅក្រម Jean-Mark LAVERGNE

ចៅក្រម **ធូ មុណី** Robert PETIT

**ជនជាប់ចោទ:**

កាំង ហ្គេកអ៊ាវ ហៅ "ឌុច"

**មេធាវីការពារក្ដីជនចាប់ចោទ:**

លោក ការ សាវុត្ថ

លោក François ROUX

លោកស្រី Marie-Paule CANIZARES

**សហព្រះរាជអាជ្ញា:**

លោកស្រី ជា លាង

លោក William SMITH

**សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:**

លោក គីម ម៉េងឃី

កញ្ញា ម៉ុច សុវណ្ណារី

លោកស្រី Martine JACQUIN

លោក Philippe CANONNE

លោកស្រី Elizabeth RABESANDRATANA

លោកស្រី Annie DELAHAIE

លោក Pierre-Olivier SUR

កញ្ញា ទី ស្រ៊ីនណា

លោក Karim KHAN

លោក Alain WERNER

លោកស្រី Brianne McGONIGLE

លោកស្រី Fabienne TRUSSES-NAPRUS

លោកស្រី Christine MARTINEAU

# I. ប្រវត្តិ

១. កាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ អង្គជំនុំជម្រះសាលាដំបូងបានចេញ "សេចក្តីណែនាំស្តីពីនីតិវិធីពាក់ព័ន្ធនឹងការទាមទារសំណង និង ការដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរបញ្ចប់ការពិភាក្សាដេញដោល"[1] ("សេចក្តីណែនាំ")។ យោងតាមសេចក្តីណែនាំនេះ ភាគីទាំងអស់ពាក់ព័ន្ធទៅនឹង ដំណើរការនីតិវិធី ត្រូវបានអញ្ជើញឱ្យដាក់សារណាចុងក្រោយ នៅក្នុងការរៀបចំធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល[2]។

២. លើសពីនេះទៅទៀត អង្គជំនុំជម្រះសាលាដំបូងបានណែនាំថា "ប្រសិនបើមាន សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរបញ្ចប់ការពិភាក្សាដេញដោលរបស់ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបញ្ជាក់ពីអំណះអំណាងផ្លូវច្បាប់ និងអង្គហេតុ ដែលគាំទ្រដល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដើម្បីឱ្យខ្លួនបានក្លាយជាដើមបណ្តឹងរដ្ឋប្បវេណី និងបញ្ជាក់ពីការទាមទារសំណងរបស់ពួកគាត់។ សេចក្តីសន្និដ្ឋាននឹងជំនួសនូវការទាមទារទាំងអស់ ដែលបានធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗនៅដំណាក់កាលមុនៗ"។[3]

៣. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសង្កេតឃើញថា ការដាក់សារណាជាលាយលក្ខណ៍អក្សរបញ្ចប់ការពិភាក្សាដេញដោល គឺជាការស្ម័គ្រចិត្ត ហើយមិនប៉ះពាល់ដល់ការដាក់សេចក្តីសន្និដ្ឋាន បញ្ចប់ការពិភាក្សាដេញដោលនោះទេ។ អាស្រ័យហេតុនេះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសន្និដ្ឋានថា ខ្លឹមសារដែលបានលើកឡើងនៅក្នុងសេចក្តីណែនាំ ទាក់ទងទៅនឹងការដាក់ជូន "អំណះអំណាងផ្លូវច្បាប់ និងអង្គហេតុ ដែលគាំទ្រដល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះ" គឺជាអនុសាសន៍ទៅវិញទេ មិនមែនជាការចងកាតព្វកិច្ច ឬអាជ្ញាបញ្ញានោះទេ។

# II. វិសាលភាពនៃសេចក្តីសន្និដ្ឋានបញ្ចប់

---

[1] រឿងក្តី កាំង ហ្គេកអ៊ាវ, សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អវតក/អជសដ, សេចក្តីណែនាំពាក់ព័ន្ធនឹងនីតិវិធីទាមទារសំណង និងការដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខអក្សរណ៍បញ្ចប់ការពិភាក្សាដេញដោល ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩, ឯកសារលេខ E159។

[2] *ដូចខាងលើ,* កថាខណ្ឌ ២។

[3] *ដូចខាងលើ,* កថាខណ្ឌ ២។

៤. តាមរយៈសារណា[4] របស់ក្រុមដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងជាទូទៅនូវទម្រង់នៃការបង្គាប់ និងសម្រេចឲ្យផ្តល់តែសំណង "ផ្លូវចិត្ត និងជាសមូហភាព" ស្របតាមវិធានផ្ទៃក្នុង ("*វិធាន*")។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម២) សូមកម្រិតសេចក្តីសន្និដ្ឋានចុងក្រោយនេះ ចំពោះសំណើសុំទាមទារសំណងឲ្យកាន់តែជាក់លាក់ប៉ុន្តែ នៅក្នុងក្របខ័ណ្ឌនៃសារណាទូទៅរបស់យើងខ្ញុំ។

៥. សំណងដែលបានស្នើសុំនេះ គឺជាលទ្ធលនៃការពិភាក្សាដ៏យូរអង្វែង ក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណី អស់រយៈពេលជាង ១៥ ខែ។ សំណើសុំនេះត្រូវបានដាក់ជូនក្នុងនាមឲ្យកូនក្តីទាំង ១៧ នាក់នៃដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម២) និងបញ្ជាក់អំពីគោលបំណងរបស់*ពួកគាត់*តែប៉ុណ្ណោះ។ ពិសេសបំផុត សារណានេះឧទ្ទិសជូនកូនក្តីក្នុងក្រុម២ ដែលជាជនរងគ្រោះដោយផ្ទាល់ ក្នុងនាមឲ្យសាច់ញាតិរបស់ពួកគាត់ ក្នុងនាមឲ្យជនរងគ្រោះដោយប្រយោល និងក្នុងនាមពួកគាត់ផ្ទាល់ ដែលជាដើមបណ្តឹងរដ្ឋប្បវេណី។

ដើមបណ្តឹងរដ្ឋប្បវេណី E2/77 បានដកពាក្យសុំរបស់គាត់ ដោយសារតែលោកស្រីយល់ថា ការិយាល័យសហចៅក្រមស៊ើបអង្កេត បានប្រព្រឹត្តមិនល្អទាល់តែសោះមកលើរូបលោកស្រី ហើយលោកស្រីមិនមានអារម្មណ៍កក់ក្តៅ ក្នុងការបន្តរឿងក្តីជាមួយសាលាក្តីនេះតទៅទៀតឡើយ។

## III. ដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធ

៦. ដើមបណ្តឹងរដ្ឋប្បវេណី ដែលគ្រាន់តែមានតួនាទីបណ្តោះអាសន្ន[5] តាំងពីដំបូងមក រួមទាំងដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានជំទាស់ដោយមេធាវីការពារក្តី[6] គួរត្រូវបានយកមកពិចារណា ដោយទទួលស្គាល់ពួកគាត់ជាដើមបណ្តឹងរដ្ឋប្បវេណី។

កាលពីថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ អង្គជំនុំជម្រះសាលាដំបូង បានទទួលសំណុំរឿងជាផ្លូវការ ប៉ុន្តែមិនបានសម្រេចទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលនៅសេសសល់នោះទេ។ បន្ថែមលើនេះទៅទៀត កាលពីថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០០៩ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

---

[4] រឿងក្តី កាំង ហ្គេកអ៊ាវ, សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អវតក/អជសង, សារណារួមគ្នារបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្តីពីការទាមទារសំណង ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៩, ឯកសារលេខ E159/3។

[5] E2/32; E2/21; E2/35; E2/22; E2/25; E2/24; E2/66; E2/62; E2/83 ។

[6] E2/22; E2/62; E2/66; E2/35; E2/83 ។

បានដាក់ឯកសារបន្ថែមស្ដីពីការទទួលយកពាក្យសុំដែលបានជំទាស់ ហើយកំពុងរង់ចាំសេចក្ដីសម្រេចនេះនៅឡើយ។

ការមិនបានចេញសេចក្ដីសម្រេចដោយអង្គជំនុំជម្រះសាលាដំបូង បានធ្វើឱ្យខូចប្រយោជន៍ដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានទន្ទឹងរង់ចាំការទទួលស្គាល់សិទ្ធិចូលរួមពេលពេញ នៅទូទាំងដំណើរការនីតិវិធី។

ការមិនបានចេញសេចក្ដីសម្រេចដោយអង្គជំនុំជម្រះសាលាដំបូង បានបង្កជាការរារាំងដល់សិទ្ធិទូទៅ និងសិទ្ធិជាមូលដ្ឋាន ដែលបានផ្ដល់ឱ្យដើមបណ្ដឹងរដ្ឋប្បវេណី គឺជាសិទ្ធិទទួលបានសេចក្ដីសម្រេចមួយឆាប់រហ័ស និងប្រកបដោយហេតុផល ទៅលើពាក្យសុំរបស់ខ្លួន ជាពិសេស ប្រសិនបើពាក្យសុំនោះទាក់ទងទៅនឹងតួនាទីទូទៅរបស់ភាគីមួយ។ អង្គជំនុំជម្រះសាលាដំបូង បានរំលោភទៅលើសិទ្ធិនេះ ដោយខកខានមិនបានចេញសេចក្ដីសម្រេច អស់រយៈពេលដប់ខែកន្លងមកហើយ។

ជាថ្មីម្ដងទៀត តំណាងដើមបណ្ដឹងរដ្ឋប្បវេណី សំណូមពរឱ្យអង្គជំនុំជម្រះសាលាដំបូងចេញសេចក្ដីសម្រេចឱ្យបានឆាប់រហ័ស និងប្រកបដោយហេតុផល ទាក់ទងទៅនឹងតួនាទីរបស់ពួកគាត់ ដើម្បីធានាឱ្យមានការចូលរួមបានពេញលេញ និងលើកកម្ពស់សុចរិតភាពនៃដំណើរការនីតិវិធី។

៧. ដោយសារលទ្ធផលនៃភាពស្ងៀមស្ងាត់របស់អង្គជំនុំជម្រះសាលាដំបូង ទៅលើរយៈពេលនៃករណីនេះ ដើមបណ្ដឹងរដ្ឋប្បវេណីដែលមានតួនាទី"បណ្ដោះអាសន្ន" ដែលមិនបានដឹងថាតើពួកគាត់មានសិទ្ធិទទួលបានសំណង ឬយ៉ាងណានោះ ប៉ុន្តែ មានសិទ្ធិធ្វើដូចគ្នានឹងដើមបណ្ដឹងរដ្ឋប្បវេណីដែរនោះ គួរត្រូវបានផ្ដល់សិទ្ធិជាដើមបណ្ដឹងរដ្ឋប្បវេណី។ ការមិនបានចេញសេចក្ដីសម្រេចទាក់ទងទៅនឹងលទ្ធភាពឱ្យពួកគាត់ចូលរួមនោះ គួរជាការសន្មត់ដោយយល់ថា បានផ្ដល់តួនាទីនេះរួចទៅហើយ។

៨. ការមិនបានដឹងច្បាស់លាស់ ក្នុងនាមជាភាគីមួយនៅក្នុងដំណើរការនីតិវិធីនេះ មិនរំលោភទៅលើសិទ្ធិរបស់ជនជាប់ចោទ នៅក្នុងលក្ខណៈណាមួយដែលគួរត្រូវបានពិចារណាថា ជាការធ្វើឱ្យខូចប្រយោជន៍នោះទេ។ បើធ្វើការប្រៀបធៀបទៅ ការធ្វើឱ្យខូចប្រយោជន៍ដល់ដើមបណ្ដឹងរដ្ឋវេណី "បណ្ដោះអាសន្ន" ដោយការមិនបានទទួលឋានៈតួនាទីក្នុងរយៈពេលប៉ុន្មានខែកន្លងមក រួមទាំងការមិនបានដឹងថាតើជនជាប់ទទួលស្គាល់តួនាទីនេះ ឬយ៉ាងណានោះ គឺវាមានផលប៉ះពាល់ជាអវិជ្ជមានមកលើពួកគាត់ធ្ងន់ធ្ងរជាងទៅលើជនជាប់ចោទ។ ជនជាប់ចោទបានប្រឈមមុខទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណី"បណ្ដោះអាសន្ន"នីមួយៗ ដូចគ្នាទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណីដែលបានទទួលស្គាល់រួចហើយដែរ។ ហេតុដូច្នេះ សំណើសុំទាមទារសំណងពីសំណាក់ដើមបណ្ដឹងរដ្ឋប្បវេណី "បណ្ដោះអាសន្ន"

មិនមានផលប៉ះបាល់អ្វីជាដុំកំភួន ឬជាការធ្វើឱ្យខូចប្រយោជន៍ទៅលើជនជាប់ចោទនោះទេ។ អាស្រ័យហេតុនេះ ក្នុងនាមឱ្យកូនក្តីរបស់យើងខ្ញុំទាំង ១៧ រូប ដូចដែលបានផ្តល់ហេតុជូនខាងលើ យើងខ្ញុំសូមធ្វើការសន្និដ្ឋាន និងសូមសំណូមពរឱ្យចាត់ទុកពួកគាត់ជាដើមបណ្តឹងរដ្ឋប្បវេណី។

## IV. សំណើទាមទារសំណង[7]

### ការសុំទោសជាលក្ខណៈរដ្ឋ

៩. ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយជនជាប់ចោទ មិនមែនជាឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយបុគ្គលម្នាក់នោះទេ ប៉ុន្តែ ជាឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន គឺជារដ្ឋដែលបានឡើងកាន់អំណាចបន្ទាប់ពីរដ្ឋមុន។

១០. ការសុំទោសខាងនយោបាយ ដែលធ្វើឡើងពីសំណាក់រដ្ឋទាំងឡាយ ចំពោះការប្រព្រឹត្តខុសឆ្គង នៅក្នុងអតីតកាល បានក្លាយទៅជាបាតុភូតនយោបាយកាន់តែច្រើនឡើងៗ ទាំងនៅក្នុងឆាកនយោបាយជាតិ និងអន្តរជាតិ នៅក្នុងសតវត្សកន្លងទៅនេះ ជាពិសេស ក្នុងរយៈពេលជាង ២០ ឆ្នាំកន្លងមកនេះ។[8]

---

[7] ការសម្រេចទៅលើទម្រង់ណាមួយនៃសំណង មិនបញ្ជាក់ពីសំណងណាមួយនោះទេ។

[8] ការសុំទោសអាចធ្វើឡើងតាមមធ្យោបាយផ្សេងៗ នៅក្នុងវង្វង់ព្រំដែន (ពីសំណាក់រដ្ឋទៅកាន់បុគ្គលទាំងឡាយ ដែលត្រូវបានគេធ្វើទុក្ខបុកម្នេញ ដូចជា ជនជាតិភាគតិច) នៅក្នុងចំណោមអ្នកនយោបាយលោកខាងលិច (ឧទាហរណ៍ ប្រទេសអាឡឺម៉ង់សុំទោសចំពោះអំពើប្រល័យពូជសាសន៍មកលើជានជាតិជ្វីសអឺរ៉ុប នៅក្នុងអំឡុងសង្គ្រាមលោកលើកទី II) អ្នកនយោបាយមិនមែនលោកខាងលិច (ឧទាហរណ៍ ប្រទេសសុំទោសចំពោះជប៉ុនចំពោះឧក្រិដ្ឋកម្មរបស់ខ្លួននៅក្នុងប្រទេសកូរ៉េ និងនៅក្នុងប្រទេសចិន នៅក្នុងបរិបទនៃសង្គ្រាមលោកលើកទី II) និងនៅក្នុងចំណោមអ្នកនយោបាយលោកខាងលិច និងមិនមែនលោកខាងលិច (ឧទាហរណ៍ ប្រទេសលោកខាងលិច សុំទោសចំពោះការធ្វើអាណានិគមមកលើប្រទេសមិនមែនលោកខាងលិច ឬសុំទោសចំពោះជំនួញទាសភាព)។

**ឧទាហរណ៍មួយចំនួនចំពោះការសុំទោសៈ**

នៅក្នុងខែកុម្ភៈ ២០០៥ ព្រឹទ្ធសភាសហរដ្ឋអាមេរិកបានសុំទោសចំពោះយុទ្ធនាការប្រឆាំងនឹងជនជាតិអាមេរិកដើមកំណើតអាហ្រ្វិក នៅស្ទើរតែទូទាំងសតវត្សកន្លងមកនេះ។

នៅថ្ងៃទី១៣ កុម្ភៈ ២០០៨ លោក ខេវីន រ៉ដ (Kevin Rudd) ដែលជានាយករដ្ឋមន្ត្រីប្រទេសអូស្ត្រាលីទើបតែជាប់ឆ្នោតថ្មីបានធ្វើការសុំទោសជាផ្លូវការចំពោះអំពើខុសឆ្គងកន្លងមក ដែលបានប្រព្រឹត្តឡើងដោយរដ្ឋាភិបាលអូស្រ្តាលីមុនៗ (successive Australian governments) មកលើជនជាតិដើមអាបូរីជីណល់ (Aboriginal)។ លោកនាយករដ្ឋមន្ត្រី រ៉ដ បានធ្វើការសុំទោសនៅក្នុងរដ្ឋសភា ដល់ជនជាតិដើមអាបូរីជីណល់ទាំងអស់ ចំពោះច្បាប់ និងគោលនយោបាយដែល "បង្កឱ្យមានទុក្ខសោក ការឈឺចាប់ និង ការបាត់បង់យ៉ាងធំធេង"។

00399826



ទម្លាប់នៃការសុំទោសជាសាធារណៈនេះ មិនត្រូវបានគេកម្រិតនោះទេនៅលោកខាងលិច។ ជាប្រវត្តិសាស្ត្រ ការសុំទោសគឺត្រូវបានយោងទៅគ្រីស្តសាសនាបែបលោកខាងលិច និងមនុស្សនិយម ប៉ុន្តែ វាមិនមែនជាការបង្កើតឡើងរបស់លោកខាងលិចនោះទេ។ មានឃន្តការសុំទោសក្រៅពីលោកខាងលិចជាច្រើន ហើយមានសារៈសំខាន់ និងលក្ខណៈដាច់ដោយឡែករបស់វា។ អាស្រ័យហេតុនេះ មិនមានហេតុផលខាងវប្បធម៌សម្រាប់ប្រទេសក្រៅពីលោកខាងលិចគេចពីការសុំទោសនោះទេ[9]។

១១. ភាពខុសគ្នាខាងផ្នែកវប្បធម៌ មិនគួរណាយកមកធ្វើជាការដោះសារ សម្រាប់បណ្តាប្រទេសក្រៅពីលោកខាងលិច ដើម្បីគេចចេញពីការសុំទោសជាសាធារណៈ ចំពោះការរំលោភសិទ្ធិមនុស្សរបស់ខ្លួននោះទេ ជាពិសេស នៅពេលដែលការសុំទោសអាចធ្វើឱ្យកូនក្តីបានធូរស្រាលពីវេទនារម្មណ៍ និងអាចចូលរួមដល់ការស្វែងរកយុត្តិធម៌បាន[10]។

១២. ប៉ុន្តែ ការសុំទោស(ជាលក្ខណៈរដ្ឋ) ត្រូវតែស្មោះត្រង់ មិនក្លែងបន្លំ និងប្រកបដោយសច្ចៈ ដើម្បីចូលរួមនៅក្នុងដំណើរការផ្សះផ្សា(ជាតិ) និង ដើម្បីឱ្យជនរងគ្រោះស្តារសេចក្តីថ្លៃថ្នូររបស់ពួកគាត់ឡើងវិញ។ ប្រសិនបើការសុំទោសនោះធ្វើឡើងសម្រាប់តែចំណាប់អារម្មណ៍ និងផលប្រយោជន៍នយោបាយទេ នោះគួរចៀសវាងការសុំទោសមិនប្រាកដប្រជា ដើម្បីកុំឱ្យជនរងគ្រោះកាន់តែឈឺចាប់ថែមទៀត។ ការសុំទោសគួរតែមានអំណាចធំមហិមា នៅពេលនិយាយទៅកាន់ជនរងគ្រោះដោយ

---

នៅខែមិថុនា ២០០៨ នាយករដ្ឋមន្ត្រីប្រទេសកាណាដា លោក ស្តេហ្វិន ហាភ័រ (Stephen Harper) បានធ្វើការសុំទោសក្នុងនាមរដ្ឋាភិបាលកាណាដា ចំពោះកម្មវិធីប្រហាក់ប្រហែលគ្នា ដែលបានផ្តួចផ្តើមឡើងនៅក្នុងចុងទសវត្សទីដប់ប្រាំបួន ដែលបានបង្ខំឱ្យមានការដកហូតយកកុមារជនជាតិភាគតិចចេញពីក្រុមគ្រួសាររបស់ពួកគេ។

នៅក្នុងខែកុម្ភៈ ២០០៨ ព្រឹទ្ធសភាសហរដ្ឋអាមេរិក បានសុំទោសចំពោះការសម្លាប់រង្គាល ដែលបានប្រព្រឹត្តឡើងដោយជនជាតិអាមេរិកកាំងដើម។

នៅចុងខែសីហា ២០០៨ នាយករដ្ឋមន្ត្រីប្រទេសអ៊ីតាលី លោក ស៊ីលវ្យ៉ូ ប៊ែរលូសកូនី (Silvio Berlusconi) បានសុំទោសប្រទេសលីប៊ី ចំពោះការខូចខាតដែលបង្កឡើងដោយប្រទេសអ៊ីតាលី នៅក្នុងសម័យអាណានិគម។

សូមមើល បញ្ជីកាលប្រវត្តិនៃការសុំទោសខាងនយោបាយ ដែលបានចងក្រងឡើងដោយលោក ហ្គ្រាហាម ជី ដតស៍ (Graham G. Dodds) ដែលបានធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី២៣ មករា ២០០៣, នៅលើគេហទំព័រ: http://www.upenn.edu/pnc/politicalapologies.html.

[9] Coicaud, Jean-Marc, ការសុំទោស: មិនមែនជាផ្នែកតូចមួយនៃយុត្តិធម៌នៅឡើយទេ, ព្រឹត្តិប័ត្រវិទ្យាសាស្ត្រនយោបាយជប៉ុន វ៉ុល្លូម ១០, លេខចេញផ្សាយ ០១ ចាប់ពីទំព័រ ៩៣-១២៤ ត្រង់ទំព័រ ១២៣។

[10] ដូចខាងលើ ត្រង់ទំព័រ ១២៤។

សារឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដែលបានប្រព្រឹត្តមកលើពួកគាត់ ដោយរដ្ឋដែលជាប្រព្រឹត្តអំពើនោះ។ ផ្ទុយពី វិធីអមនុស្សធម៌ ដែលប្រៀបបាននឹងឧបករណ៍ដ៏ពោពេញទៅដោយអំណាចមួយនៃសង្គ្រាម សុខដុម នីយកម្មគឺជា ឧបករណ៍ដ៏មានសារៈសំខាន់មួយសម្រាប់ការផ្សះផ្សា ដែលចូលរួមចំណែកដល់ដំណើរ សម្រុះសម្រួលនេះ[11]។

១៣. ចំពោះហេតុផលដែលបានលើកឡើងរួចមកហើយនេះ ដើមបណ្តឹងរដ្ឋប្បវេណីជឿជាក់ថា វាដល់ពេលវេលាសម្រាប់រដ្ឋាភិបាលកម្ពុជាធ្វើការសុំទោសដោយស្មោះត្រង់ ឥតក្លែងបន្លំ និងសច្ចៈ ចំពោះ ឧក្រិដ្ឋកម្មដ៏សាហាវយល់ឃ្នង ដែលបានប្រព្រឹត្តនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ បន្ទាប់ពី ការស្ថិតនៅក្នុងភាពស្ងៀមស្ងាត់អស់រយៈពេលជាង ៣០ ឆ្នាំកន្លងមកនេះ។

១៤. ជនជាប់ចោទគួរចូលរួមនៅក្នុងដំណើរការនេះ ដោយការសរសេរលិខិតបើកចំហរមួយផ្ញើជូនទៅ រាជរដ្ឋាភិបាល ដែលក្នុងនោះ គាត់ត្រូវធ្វើការសុំទោសដោយផ្ទាល់ចំពោះដើមបណ្តឹងរដ្ឋប្បវេណី ជាផ្លូវការ ស្មោះត្រង់ ឥតក្លែងបន្លំ និងសច្ចៈ សម្រាប់ហេតុផលដែលបានលើកឡើងមកនេះ។

## បូជនីយស្ថានសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី និងសាច់ញាតិរបស់ពួកគាត់ ត្រូវមានទីតាំងនៅមន្ទីរឃុំឃាំង ស-២១ និង ជើងឯក

១៥. ដើម្បីរក្សាការចងចាំដល់ការជំនុំជម្រះក្តីទីមួយនៅចំពោះមុខ អវតក និង ដើម្បីរំលឹកដល់ក្រុមដើម បណ្តឹងរដ្ឋប្បវេណីដំបូង នៅក្នុងដំណើរការនីតិវិធីនេះ ឈ្មោះរបស់ដើមបណ្តឹងរដ្ឋវេណីដែល រស់រាន មានជីវិតដោយផ្ទាល់ និងឈ្មោះរបស់ដើមបណ្តឹងរដ្ឋវេណី ជាមួយនឹងសាច់ញាតិដែលត្រូវបាន សម្លាប់ ឬបានស្លាប់នៅមន្ទីរឃុំឃាំង ស-២១ និង/ឬ ជើងឯក គួរតែត្រូវបានឆ្លាក់ជាអក្សរពណ៌ខ្មៅ នៅលើថ្មម៉ាបពណ៌ស។ ក្រៅពីឈ្មោះរបស់ពួកគាត់ ការឆ្លាក់អក្សរនេះគួរតែដាក់បញ្ចូលនូវកាលបរិច្ឆេទ នៃការចូលមកដល់មន្ទីរឃុំឃាំង ស-២១ និង/ឬ កាលបរិច្ឆេទនៃការស្លាប់របស់ពួកគាត់ និង/ឬ មូលហេតុ និង/ឬ ទីកន្លែងនៃការស្លាប់របស់ពួកគាត់។ ជាមួយនេះផងដែរ ព័ត៌មានខ្លះៗទាក់ទងទៅនឹងបុគ្គលិក លក្ខណៈ និងខ្សែជីវិតរបស់ជនរងគ្រោះ គួរតែត្រូវបានដាក់បញ្ចូលផងដែរ។ អត្ថបទដែលសរសេរ ដោយដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ មិនគួរឲ្យលើសពី ២០០ រយពាក្យទេ និងត្រូវដាក់បង្ហាញនៅ លើផ្ទាំងសិលាបន្ថែម (មួយផ្ទាំងសម្រាប់បុគ្គលម្នាក់/មួយគ្រួសារ) រួមទាំងដំណើររឿងរ៉ាវ និងរូបថត

---

[11] ដូចខាងលើ ត្រង់ទំព័រ ១២៤។

របស់ជនរងគ្រោះមួយសន្លឹកផង។ អត្ថបទនេះក៏គួរត្រូវបានសរសេរ និងផ្តល់ជូនជាការថតសម្លេង ជាភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង ដែលលជាភាសាការងាររបស់ អវតក។

ផ្ទាំងសិលាជាបូជនីយស្ថាននេះ គួរតែតម្លើងនៅក្នុងបរិវេណសារមន្ទីរទួលស្លែង និងនៅចំហៀងខាងឆ្វេង និងខាងស្តាំនៃចេតិយនៅជើងឯក។ ផ្ទាំងសិលាបូជនីយស្ថានទីមួយៗគួរតែដាក់បញ្ចូលនូវសេចក្តីសង្ខេបខ្លីមួយ ព្រមទាំងការជំនុំជម្រះលើកដំបូងនៅ អវតក (ដោយមិនឱ្យលើសពី ៣០០ ពាក្យ) សម្រាប់ជាការរំលឹកដល់ដើមបណ្តឹងរដ្ឋប្បវេណី និងសាច់ញាតិរបស់ពួកគាត់ ដែលបានបាត់បង់ជីវិតនៅក្រោមការបញ្ជារបស់ជនជាប់ចោទ កាំង ហ្កេកអ៊ាវ។

## បូជនីយស្ថានរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅព្រៃស

១៦. ព្រៃស (ស-២៤) ដែលជាអតីតមណ្ឌលអប់រំកែប្រែ មិនទាន់ក្លាយជាទីតាំងបូជនីយស្ថាននៅឡើយទេ។ ទីតាំងបូជនីយស្ថាននាពេលអនាគត គួរតែជាកន្លែងសម្រាប់រំលឹក ធ្វើការគោរព និងរៀបចំពិធីបុណ្យទានបែបព្រះពុទ្ធសាសនា។ ក្រៅពីនេះ វាគួរតែជាកន្លែងផ្តល់នូវព័ត៌មានស្តីពីប្រវត្តិសាស្ត្រ និងប្រើប្រាស់ជាមជ្ឈមណ្ឌលអប់រំរៀនសូត្រនាពេលអនាគត។ គម្រោងទីតាំងបូជនីយស្ថាននេះគួរតែសម្រេចឡើងដោយការប្រគួតប្រជែងដេញថ្លៃផ្នែកស្ថាបត្យកម្មជាអន្តរជាតិ។ ក្រោយពីទទួលបានសំណើដេញថ្លៃក្នុងស្រុក និងអន្តរជាតិរួចមក ដើមបណ្តឹងរដ្ឋប្បវេណីអាចសម្រេចថាតើសំណើដេញថ្លៃណាមួយដែលខ្លួនពេញចិត្ត។ ចក្ខុវិស្ស័យនៃបូជនីយស្ថាននេះ គឺជាការរួមបញ្ចូលគ្នានូវបូរាណភាព និងទំនើបកម្ម និងដើម្បីបំពេញតម្រូវការនៃការរំលឹកការចងចាំ ពិធីបុណ្យសាសនា និងការអប់រំ។

យ៉ាងហោចណាស់ ក៏គួររាប់បញ្ចូលនូវចំណុចដូចខាងក្រោមនេះ៖ នៅក្រោមការបញ្ជារបស់ជនជាប់ចោទ គួរសង់ស្តូបមួយសម្រាប់ទីតាំងប្រើប្រាស់ជាបូនីយស្ថាន ដែលយ៉ាងហោចណាស់ត្រូវមានទំហំ ២០ ម៉ែត្រ បួនជ្រុង និងមានកម្ពស់ ៣៥ ម៉ែត្រ។ ផ្នែកខាងក្នុងនៃស្តូបនេះគួរតែ អាចឱ្យប្រារព្ធពិធីបុណ្យបែបព្រះពុទ្ធសានា សម្រាប់ជនរងគ្រោះដែលត្រូវបានគេសម្លាប់ ដែល បានស្លាប់ និងដែលត្រូវបានគេប្រព្រឹត្តយ៉ាងអនុស្សធម៌មកលើខ្លួន។ បន្ថែមលើនេះទៀត គួរតែមានការដាក់ បង្ហាញជាអចិន្ត្រៃយ៍ដោយមានការពន្យល់ឱ្យដឹងពីមុខងារ និងតួនាទីរបស់មន្ទីរឃុំឃាំងព្រៃស ដូចដែល បានលើកឡើងនៅក្នុងសវនាការជំនុំជម្រះលើកដំបូង នៅ អវតក និង អនុលោមតាមលទ្ធផលសិក្សាស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ។ ការស្វែងរកការពិតជាប្រវត្តិសាស្ត្រនេះ គួរត្រូវបានបង្ហាញនៅក្នុង

ភាសាការងារទាំងបីរបស់ អវតក ដែលអាចរកបាន ទាំងនៅក្នុង ទម្រង់សំណេរ និង ក្នុងខ្សែអាត់ផង។ តួនាទី និងការទទួលខុសត្រូវរបស់ជនជាប់ចោទ គួរត្រូវបានពន្យល់នៅលើផ្ទាំងថ្ម រួមទាំងផែនទីមួយដោយមានការរៀបរាប់អំពីទីតាំងនេះ។ លើសពី នេះទៅទៀត គួរតែបង្ហាញឈ្មោះរបស់ដើមបណ្តឹងរដ្ឋវេណី ដោយមានការពន្យល់អំពីតួនាទីរបស់ ពួកគាត់ នៅក្នុងរឿងក្តីប្រឆាំងនឹងជនជាប់ចោទ។ អត្ថបទនេះគួរសរសេរឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី។

## ការធ្វើទស្សនកិច្ចរបស់ដើមបណ្តឹងរដ្ឋប្បវេណី

## នៅទីតាំងបូជនីយស្ថាន ទួលស្លែង ជើងឯក និង ព្រៃស

១៧. ដោយហេតុថា មិនមែនដើមបណ្តឹងរដ្ឋប្បវេណីសុទ្ធតែរស់នៅក្នុងរាជធានីភ្នំពេញទាំងអស់គ្នា ឬនៅជិតបូជនីយស្ថានដែលបានលើកឡើង នោះដើមបណ្តឹងរដ្ឋប្បវេណី គួរមានឱកាសមកធ្វើទស្សនកិច្ចដោយការបង់ប្រាក់ជំនួស នៅបូជនីយស្ថានទួលស្លែង ជើងឯក និង ព្រៃស បីដងក្នុងមួយឆ្នាំ ដែលក្នុងម្តងៗមានរយៈពេលបួនថ្ងៃ។ អត្ថប្រយោជន៍នេះគួររួមបញ្ចូលនូវសិទ្ធិអនុញ្ញាតឱ្យជនណាម្នាក់មកធ្វើទស្សនកិច្ចជំនួសដើមបណ្តឹងរដ្ឋប្បវេណី និង/ឬ អនុញ្ញាតឱ្យជនណាម្នាក់អមដំណើរដើមបណ្តឹងរដ្ឋប្បវេណី ប្រសិនបើចាំបាច់។

## ការព្យាបាលផ្នែកវេជ្ជសាស្ត្រ និង សេវាចិត្តសាស្ត្រសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី

១៨. អ្នករស់រានមានជីវិតដោយផ្ទាល់ពីមន្ទីរ ស-២១ និង ស-២៤ ស្នើសុំសិទ្ធិទូទៅ ដើម្បីទទួលបានការព្យាបាលផ្នែកវេជ្ជសាស្ត្រ និងការគាំទ្រផ្នែកចិត្តសាស្ត្រ ប្រសិនមាន។ ជនជាប់ចោទគួរចេញសោហ៊ុយព្យាបាល ថ្លៃថ្នាំ ហើយបើចាំបាច់ គួរចេញសោហ៊ុយធ្វើដំណើរទៅកាន់ទីតាំងសមស្របណាមួយ។

ជនរងគ្រោះដោយប្រយោលពីមន្ទីរ ស-២១ និង ស-២៤ ដែលមិនបានទទួលរងការឈឺចាប់ដោយផ្ទាល់ខ្លួន និងពីរបបខ្មែរក្រហមដោយផ្ទាល់នោះ គួរតែត្រូវបង្ហាញឱ្យឃើញថា ការឈឺចាប់របស់ពួកគាត់គឺបណ្តាលមកពី ឬអាចបណ្តាលមកពីរបបកម្ពុជាប្រជាធិបតេយ្យ។ ប្រសិនបើពួកគាត់បានផ្តល់ភស្តុតាងបឋមដែលអាចទទួលយកបាន នោះគួរតែផ្តល់សិទ្ធិឱ្យពួកគាត់ទទួលបានការព្យាបាលផ្នែកវេជ្ជសាស្ត្រ និងការគាំទ្រផ្នែកចិត្តសាស្ត្រ ដូចជនរងគ្រោះផងដែរ។

## ការកសាងការយល់ដឹងអំពីប្រវត្តិសាវតា និង លទ្ធផលនៃការជំនុំជម្រះក្តី

១៩. ការថតយកសំឡេង និងថតវីដេអូ នូវផ្នែកសំខាន់ៗនៃការជំនុំជម្រះក្តី គួរតែត្រូវបាធ្វើឡើងជាសង្ខេប ដែលមានរយៈពេលយ៉ាងហោចណាស់ក៏ ១០០ ម៉ោងដែរ។ ការថតយកសំឡេង និងថតវីដេអូក៏គួរដាក់បញ្ចូលនូវការពន្យល់ពីតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងថែមទាំងផ្តល់សិទ្ធិធ្វើការកែប្រែឱ្យពួកគាត់។ ការថតយកសំឡេង និងថតវីដេអូនេះ គួរតែត្រូវបានថតជាប្រាំច្បាប់ចម្លង និងចែកចាយ ទៅតាមខេត្ត និងឃុំទាំងអស់ ដើម្បីអប់រំ និងជូនដំណឹងឱ្យប្រជាពលរដ្ឋកម្ពុជាទាំងអស់បានដឹង។ ហោចណាស់ក៏គួរផ្តល់រូបថតចំនួនដប់សន្លឹកទៅឱ្យឃុំនីមួយៗ និងដាក់បង្ហាញរូបថតនៅក្នុងវត្តអារាមមួយ ព្រមទាំងឯកសារសំណេរ និងឯកសារថតជាសម្លេងនៃសាលក្រមស្ថាពរ ដែលត្រូវដាក់តាំងបង្ហាញនៅក្នុងវត្តមួយ ក្នុងមួយឃុំ។

## ការយកឈ្មោះជនរងគ្រោះទៅដាក់ឈ្មោះអាគារសាធារណៈ ដើម្បីជាការរំលឹកដល់ជនរងគ្រោះ

២០. ដើមបណ្តឹងរដ្ឋប្បវេណីមួយរូបៗ គួរមានសិទ្ធិជ្រើសរើសអាគារសាធារណៈ ដូចជា មន្ទីរពេទ្យ ឬសាលារៀនដើម្បីដាក់ឈ្មោះជនរងគ្រោះ ដែលគាត់បានធ្វើជាតំណាងឱ្យ។ ដំណើរការនេះគួរតែរំលឹកដោយការប្រារព្ធពិធីបុណ្យជាសាធារណៈ។ គួររាប់បញ្ចូលនូវប្ញូជនីយស្ថានជារូបវ័ន្ត រួមមាន ឈ្មោះរបស់ជនរងគ្រោះ និងសុន្ទរកថារៀបរាប់ដំណើររឿងរបស់គាត់ ដែលបានលើកឡើងនៅក្នុងពិធីនេះ។ ប្ញូជនីយស្ថានជារូបវ័ន្តនេះ គួរដាក់បញ្ចូលនូវព័ត៌មានស្តីពីជោគវាសនារបស់ជនរងគ្រោះនៅមន្ទីរស-២១ នៅជើងឯក និង/ឬ នៅព្រៃស។ ពិធីនេះគួរត្រូវបានចាក់ផ្សាយ ហើយកាសែតវីដេអូចាក់ផ្សាយមួយច្បាប់គួររក្សាទុកនៅសារមន្ទីរទួលស្លែង ជើងឯក និងសារមន្ទីរថ្មី នៅព្រៃស។

អាស្រ័យហេតុនេះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម២) សំណូមពរឱ្យអង្គជំនុំជម្រះសាលាដំបូង៖

(១) ប្រកាសទទួលយកភ្លាមៗនូវដើមបណ្តឹងរដ្ឋប្បវេណី "បណ្តោះអាសន្ន" ដែលជាលទ្ធផលនៃការសន្មតមិនច្បាស់លាស់ពីភាពអាចទទួលយកបាន។

(២) ផ្តន្ទាទោសជនជាប់ចោទ ដោយមិនគិតចំណូល និង/ឬ ទ្រព្យសម្បត្តិសព្វថ្ងៃរបស់គាត់ ក្នុងការទទួលខុសត្រូវលើសំណងដូចមានរាយខាងក្រោម ដែលបានរៀបរាប់ខាងលើរួចមកហើយ៖

(i) សរសេរលិខិតមួយច្បាប់ផ្ញើជូនទៅរាជរដ្ឋាភិបាលកម្ពុជា ជាមួយនឹងការសុំទោសជាផ្លូវរដ្ឋមួយដែលស្មោះត្រង់ ឥតក្លែងបន្លំ និងប្រកបដោយសច្ចៈ ក្នុងនាមឲ្យដើមបណ្តឹងរដ្ឋវេណីដែលបានធ្វើការស្នើសុំនេះ។

(ii) តម្កើងផ្ទាំងថ្មជាបូជនីយស្ថានជូនដល់ដើមបណ្តឹងរដ្ឋវេណី និង សាច់ញាត់របស់ពួកគាត់ និងការតម្កើងផ្ទាំងថ្មព័ត៌មាន រួមទាំងការផ្តល់ជូននូវការថតសំឡេង និងការបកប្រែ។

(iii) រៀបចំឱ្យមានការប្រគួតប្រជែងជេញថ្លៃផ្នែកស្ថាបត្យកម្មជាអន្តរជាតិ កសាងស្តូបមួយ សារមន្ទីរមួយ នៅលើអតីតទីតាំងមន្ទីរអប់រំកែប្រែព្រៃស។

(iv) ប្រសិនបើចាំបាច់ ទទួលបានការធ្វើទស្សនកិច្ចដោយមានការបង់ប្រាក់ជំនួសយ៉ាង ហោចណាស់ក៏សម្រាប់ដើមបណ្តឹងរដ្ឋវេណីចំនួន ១៣ នាក់ ដោយមានអ្នកអមដំណើរ ដែលមិនមែនជាអ្នករស់នៅទីក្រុងភ្នំពេញ ទៅកាន់សារមន្ទីរទួលស្លែង ព្រៃស និងជើងឯក បីដងក្នុងមួយឆ្នាំ ហើយការធ្វើទស្សនកិច្ចម្តងៗមានរយៈពេលបួនថ្ងៃ។

(v) ការព្យាបាលផ្នែកវេជ្ជសាស្ត្រ ថ្នាំពេទ្យ និងសេវាផ្នែកចិត្តសាស្ត្រសម្រាប់អ្នករស់រានមានជីវិតពីទួលស្លែង ព្រៃស និងជើងឯក ប្រសិនបើមាន និងអ្នករស់រានមានជីវិតដោយប្រយោល ប្រសិនបើ ជម្ងឺនោះពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង។

(vi) ការថតខ្សែភាពយន្តឯកសារខ្លី យ៉ាងហោចណាស់មានរយៈពេល ១០០ ម៉ោង ស្តីពីសវនាការ ការផ្តល់សាលក្រមជាលាយលក្ខណ៍អក្សរ និងថតជាសំឡេងចំនួន ១០ ច្បាប់ សម្រាប់វត្តមួយក្នុងមួយឃុំ ចាត់ចែងការបញ្ជូនទៅតាមបណ្តាខេត្តនានា និងបញ្ចាំងខ្សែភាពយន្តឲ្យបានទៀងទាត់។

(vii) ប្រារព្ធពិធីរំលឹកការដាក់ឈ្មោះអាគារសាធារណៈឲ្យបានចំនួន ១៧ លើក បង្កើត និងតម្កើងផ្ទាំងព័ត៌មាន។

សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម២) សូមដាក់ជូនសេចក្តីសន្និដ្ឋានចុងក្រោយនេះដោយក្តីគោរពដ៏ខ្ពង់ខ្ពស់។

E159/6



| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ០៥ តុលា ២០០៩ | សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖<br>ហុង គឹមសួន<br>គង់ ពិសី<br>យុង ផានិត<br>Silke Studzinsky | រាជធានីភ្នំពេញ | |